# អង្គការតម្លាភាពកម្ពុជា

## ការប្រកួតប្រជែងអត្ថបទសំណេរ
## «គណនេយ្យភាពសារពើពន្ធសម្រាប់ការកាត់បន្ថយវិសមភាព»

- អ្នកនិពន្ធដែលមានចំណាប់អារម្មណ៍ចង់ចូលរួមប្រកួតប្រជែងត្រូវជ្រើសរើសយកតែមួយក្នុងចំណោមប្រធានបទដែលបានស្នើខាងក្រោម
- អ្នកនិពន្ធមិនត្រូវបានអនុញ្ញាតឱ្យជ្រើសរើសប្រធានបទខាងក្រៅដទៃផ្សេងទៀតឡើយ បើទោះបីជាប្រធានបទនោះមានការពាក់ព័ន្ធ និងភាពស្រដៀងគ្នាទៅនឹងប្រធានបទគោលនៃការប្រកួតទាំងមូលក៏ដោយ

## I. ប្រធានបទ៖

1. តើអ្វីទៅជាតួនាទីនៃការប្រមូលពន្ធរបស់កម្ពុជាដើម្បីទូទាត់សងនូវផលប៉ះពាល់សេដ្ឋកិច្ចដែលកើតចេញពីការបាត់បង់នៃការដកផ្នែកខ្លះនៃគោលការណ៍អនុគ្រោះពន្ធទាំងអស់លើកលែងតែសព្វាវុធ (EBA)?
2. តើកម្ពុជាគួរអនុវត្តគោលនយោបាយសារពើពន្ធបែបណាដើម្បីធានាឱ្យបាននូវការគោរពពន្ធសាជីវកម្ម?
3. តើគណនេយ្យភាពសារពើពន្ធសម្រាប់ការកាត់បន្ថយវិសមភាពគឺជាអ្វី? ហើយតើគោលការណ៍នេះរួមចំណែកក្នុងការកាត់បន្ថយវិសមភាពសង្គមតាមរបៀបណាខ្លះ?
4. តើការប្រមូលពន្ធរបស់កម្ពុជាដើរតួនាទីបែបណាក្នុងការរៀបចំប្រទេសឱ្យក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០?
5. តើអ្នកយល់យ៉ាងណាចំពោះការប្តេជ្ញារបស់រដ្ឋាភិបាលក្នុងការប្រមូលចំណូលពន្ធឱ្យបាន២០%បន្ថែមក្នុងឆ្នាំ២០២០ ក្រោយមានការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩?

6. បើសិនអ្នកគឺជាអ្នកធ្វើគោលនយោបាយ តើអ្នកនឹងដាក់ចេញនូវគោលនយោបាយសារពើពន្ធបែបណាដើម្បីបង្កើនចំណូលពន្ធជូនប្រទេសកម្ពុជាសម្រាប់ឆ្នាំ២០២១?

## II. ជ័យលាភី

អង្គការតម្លាភាពកម្ពុជា នឹងធ្វើការជ្រើសរើសជ័យលាភីសំណេរឆ្នើមចំនួន ៣រូបៈ

- ជ័យលាភីលេខ១ នឹងទទួលបានថវិកាចំនួន $៤៥០
- ជ័យលាភីលេខ២ នឹងទទួលបានថវិកាចំនួន $៣៥០
- ជ័យលាភីលេខ៣ នឹងទទួលបានថវិកាចំនួន $២៥០

## III. លក្ខខណ្ឌក្នុងការចូលរួមប្រកួតៈ

- ជានិស្សិតសាកលវិទ្យាល័យនានានៅប្រទេសកម្ពុជា ដែលមានអាយុចន្លោះពី ១៨ ទៅ ៣០ ឆ្នាំ
- មានទីលំនៅបច្ចុប្បន្នក្នុងប្រទេសកម្ពុជា
- អត្ថបទសំណេរត្រូវតែជាការងារបុគ្គល

## IV. លក្ខខណ្ឌក្នុងការដាក់ពាក្យៈ

- អត្ថបទសំណេរត្រូវតែឆ្លើយតប និងពន្យល់អំពីប្រធានបទដែលត្រូវបានជ្រើសរើស
- អត្ថបទសំណេរត្រូវតែមានការផ្តល់ដំណោះស្រាយ និងអនុសាសន៍យ៉ាងតិច៣ចំណុច ចំពោះបញ្ហាដែលចោទនៅក្នុងប្រធានបទមុននឹងធ្វើសេចក្តីសង្ខេបបញ្ចប់
- អត្ថបទសំណេរត្រូវតែជាស្នាដៃដើមរបស់បុគ្គល ដោយមិនមានការថតចម្លងពីអ្នកដទៃ និងពីប្រភពណាទាំងអស់
- អត្ថបទសំណេរគួរត្រូវបានប្រើស្ថិតិ ទិន្នន័យ តារាង និងព័ត៌មានផ្សេងទៀតដើម្បីគាំទ្រ អំនះអំណាងផ្សេងៗដែលលើកឡើង
- ប្រើការសម្រង់ពាក្យសម្តីរបស់អ្នកនិពន្ធដើមឱ្យបានត្រឹមត្រូវតាមស្តង់ដារដែលបានកំណត់ខាងក្រោម
- អ្នកនិពន្ធអត្ថបទត្រូវទទួលខុសត្រូវចំពោះការស្រាវជ្រាវស៊ីជម្រៅដោយខ្លួនឯងសម្រាប់ប្រធានបទដែលបានជ្រើសរើស

- រាល់ព័ត៌មានដែលបានសរសេរនៅក្នុងអត្ថបទសំណេរត្រូវតែមានភាពពិតប្រាកដ ជាក់លាក់ និងអាចស្រាវជ្រាវបន្តបាន

## V. របៀបនៃការដាក់ពាក្យ៖

- អត្ថបទសំណេរដែលផ្ញើមកត្រូវតែជាប្រភេទ pdf និង docx (២ ឯកសារ) ក្នុងអ៊ីម៉ែល តែមួយ
- ផ្ញើអត្ថបទសំណេរមកកាន់អ៊ីម៉ែល lymengchi@ticambodia.org ដោយមានការប្រាប់នូវព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកនិពន្ធក្នុងសំណើរនៅលើអ៊ីម៉ែលដែលមាន ដូចជា៖ ប្រធានបទនៃអត្ថបទសំណេរ ឈ្មោះអ្នកនិពន្ធ ភេទ ថ្ងៃ/ខែ/ឆ្នាំកំណើត អាស័យដ្ឋានបច្ចុប្បន្ន សាកលវិទ្យាល័យ លេខទូរស័ព្ទទំនាក់ទំនង អ៊ីម៉ែល និងកិច្ចព្រមព្រាង តាមទម្រង់ដូចមានបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម៖
  - ប្រធានបទ៖ ……………………………………………..
  - ឈ្មោះ៖ **ជី លីម៉េង**
  - ភេទ៖ **ប្រុស**
  - ថ្ងៃ/ខែ/ឆ្នាំកំណើត៖ **២៦ ឧសភា ២០២០**
  - អាស័យដ្ឋានបច្ចុប្បន្ន៖ **ភ្នំពេញ**
  - សាកលវិទ្យាល័យ៖ **សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**
  - លេខទូរស័ព្ទទំនាក់ទំនង៖ **០៧០ ៧៩៩ ៥៤២**
  - អ៊ីម៉ែល៖ lymengchi996@gmail.com
  - កិច្ចព្រមព្រាង៖ ដោយចូលរួមក្នុងការប្រកួតប្រជែងនេះ ខ្ញុំបាទ/នាងខ្ញុំ ព្រមទទួលយកលក្ខខណ្ឌដែលមានចែងក្នុងទម្រង់ពាក្យស្នើសុំ និងយល់ព្រមអនុវត្តតាមការសម្រេចចិត្តចុងក្រោយរបស់គណៈកម្មាធិការវាយតម្លៃ និងដាក់ពិន្ទុ ដោយមិនមាននូវការជំទាស់តវ៉ាផ្សេងៗ
- ផ្ញើមកជាមួយនូវកាតសំគាល់ខ្លួននិស្សិតដែលបានស្កេន

## VI. កំណត់សម្គាល់

- អ្នកនិពន្ធអាចផ្ញើអត្ថបទសំណេរបានតែមួយដងតែប៉ុណ្ណោះ (ការផ្ញើអត្ថបទសំណេរទ្វេដងនឹងមិនត្រូវបានពិចារណាសម្រាប់អត្ថបទសំណេរដែលបានផ្ញើជាលើកទី២)

- អង្គការតម្លាភាពកម្ពុជា រក្សាសិទ្ធិក្នុងការប្រើប្រាស់អត្ថបទសំណេរ ដែលទទួលបានជ័យលាភី ឬ មិនទទួលបានជ័យលាភីសម្រាប់ការប្រើប្រាស់ និងផ្សព្វផ្សាយបន្ត
- អ្នកនិពន្ធដែលបំពេញគ្រប់លក្ខណ្ឌខាងលើ និងអត្ថបទសំណេរដែលគោរពតាមទ្រង់ទ្រាយដូចបានបញ្ជាក់ ទើបត្រូវបានទទួលយកមកពិចារណា។

## VII. ទ្រង់ទ្រាយអត្ថបទសំណេរ

- អត្ថបទសំណេរត្រូវតែជាភាសាខ្មែរ
- ៣ទំព័រអតិបរមា ដែលមិនរាប់បញ្ចូលរូបភាព និងក្រាហ្វ (សំណេរតែប៉ុណ្ណោះ)
- ទំហំក្រដាស A4
- Normal Margin (១ inch ១ inch ១ inch និង១ inch)
- ពុម្ពអក្សរខ្មែរ អូអេស (Khmer OS)
- ទំហំអក្សរ១២ សម្រាប់អត្ថបទសំណេរ និង១៤ សម្រាប់ចំណងជើង
- គម្លាតជួរអក្សរ (Double spacing)
- ការដកស្រង់អត្ថបទ (in-text citation) នាមត្រកូលរបស់អ្នកនិពន្ធដើម និងឆ្នាំនៃការបោះពុម្ព (ការដកស្រង់អត្ថបទអាចធ្វើជាភាសាអង់គ្លេសបានតាមទម្រង់ APA) **ឧទាហរណ៍៖** បណ្តាញសង្គមហ្វេសប៊ុកគឺជាបណ្តាញសង្គមដែលមានអ្នកប្រើប្រាស់ច្រើនជាងគេបំផុតក្នុងទស្សវត្សឆ្នាំ២០២០នេះ (Mark, 2020)។
- ការយោង (referencing) (ចម្លងបញ្ចូលតំណភ្ជាប់ដាក់ក្នុងទំព័រចុងក្រោយនៃអត្ថបទសំណេរ)

## VIII. លក្ខន្តិកក្នុងការវិនិច្ឆ័យជ្រើសរើស

- ការប្រើប្រាស់ពាក្យពេជ្រ ឃ្លាឃ្លោង ១០%
- លំហូរនៃមាតិការួមមាន៖ ផ្តើមសេចក្តី (លំនាំបញ្ហា ចំណូលបញ្ហា និងចំណោទបញ្ហា) តួសេចក្តី (ដំណោះស្រាយបញ្ហា) និងបញ្ចប់សេចក្តី (សេចក្តីសង្ខេបសរុប និងអនុសាសន៍) ១៥%
- អត្ថន័យ និងខ្លឹមសារនៃអត្ថបទសំណេរ ២៥%

- ការផ្តល់នូវដំណោះស្រាយបញ្ហាដែលបានចោទសួរនៅក្នុងប្រធានបទ ប្រកបដោយភាពអាចធ្វើទៅបាន ប្រសិទ្ធភាព និងប្រសិទ្ធផល ៤០%
- បទបង្ហាញស្តីពីការរកឃើញសំខាន់ៗ ១០% ។